MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

សម្រាប់ការចេញផ្សាយបន្ទាន់

# គណៈកម្មការទន្លេមេគង្គផ្តល់រង្វាន់ដល់ជ័យលាភីនៃការប្រកួតនិពន្ធរឿងខ្លី ដើម្បីអបអរសាទរគុណតម្លៃរួមរបស់ទន្លេមេគង្គ, លើកកម្ពស់ផែនការ និងការគ្រប់គ្រងប្រកបដោយបរិយាបន្ន

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៨** – ថ្ងៃនេះ គណៈកម្មការទន្លេមេគង្គ បានផ្តល់រង្វាន់ដល់ជ័យលាភីក្នុងការប្រកួតនិពន្ធរឿងខ្លី ដើម្បីអបអរសាទរគុណតម្លៃ និងធនធានរួមរបស់ទន្លេមេគង្គ និងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការសម្របសម្រួលការរៀបចំផែនការ និងការគ្រប់គ្រងតំបន់អាងទន្លេនេះ។

ជ័យលាភី រួមមានពលរដ្ឋមកពីប្រទេសជាប់ទន្លេមេគង្គចំនួន ៥ រូប ដែលត្រូវបានជ្រើសរើសពីបេក្ខជនមួយក្រុមមានគ្នាជាង ៣០០ នាក់ ដែលបានចូលរួមក្នុងការប្រកួតប្រជែងសំណេរនេះ ជាមួយនឹងសំណួរ "តើទន្លេមេគង្គមានន័យយ៉ាងដូចម្តេចចំពោះអ្នក?"។ ពលរដ្ឋខ្មែរទទួលបានចំណាត់ថ្នាក់លេខ ១ និងលេខ ៤ ជាមួយនឹងរង្វាន់ ៣០០ ដុល្លារ សម្រាប់ជ័យលាភីលេខ ១ និង ៥០ ដុល្លារ សម្រាប់ជ័យលាភីលេខ ៤។ ពលរដ្ឋមកពីប្រទេសថៃ ទទួលបានជ័យលាភីលេខ ២, វៀតណាមទទួលបានជ័យលាភីលេខ ៣ និងពីប្រទេសឡាវទទួលបានជ័យលាភីលេខ ៥ ដោយពួកគេម្នាក់ៗទទួលបានប្រាក់ ៥០ ដុល្លារ។ ជ័យលាភី ៧ នាក់ផ្សេងទៀត ទទួលរង្វាន់ជាជ័យលាភីបម្រុង និងបានទទួលប័ណ្ណសរសើរ។

ជ័យលាភីទាំងនេះ បានលើកឡើងពីគុណតម្លៃរួមនៃទន្លេមេគង្គ និងតួនាទីដ៏សំខាន់របស់គណៈកម្មការទន្លេមេគង្គ ខណៈពេលពេលពួកគេមកទទួលរង្វាន់នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ក្នុងទីក្រុងវៀងចន្ទ។

កញ្ញា អ៊ឹង អ៊ុយលីម និស្សិតមកពីវិទ្យាស្ថានភាសាបរទេសនៃប្រទេសកម្ពុជា ដែលឈ្នះរង្វាន់លេខ ១ បាននិយាយថា "ទន្លេមេគង្គ គឺជាប្រភពនៃជីវិត ដែលប្រៀបបានទៅនឹងទឹកអម្រិត។ ទន្លេនេះផ្តល់អាហារដល់មនុស្សរាប់លាននាក់ និងអាចដំណើរការទៅបានប្រកបដោយនិរន្តរភាព តែតាមរយៈការបំពេញតួនាទីរបស់ស្ថាប័ន ដូចជា MRC ប៉ុណ្ណោះ"។

"ទន្លេមេគង្គជួយជំរុញសេដ្ឋកិច្ចរបស់តំបន់នេះ និងផ្តល់ការទំនុកបម្រុងដល់ជីវិត។ ទន្លេនេះដូចជាសរសៃឈាម ដែលពោរពេញដោយសារធាតុចិញ្ចឹម ជួយទ្រទ្រង់ជីវិតគ្រប់សរីរាង្គទាំងអស់។ ខ្ញុំមិនអាចស្រមៃឃើញអំពីអ្វីដែលនឹងកើតមានឡើងនោះឡើយ ប្រសិនបើពុំមានគណៈកម្មការទន្លេមេគង្គនោះទេ" នេះបើតាមសម្តីរបស់កញ្ញា Souliphone Dalavong ជ័យលាភីលេខ ៥ មកពីប្រទេសឡាវ

ក្នុងពិធីនេះ ដែលមានការចូលរួមពីមនុស្សជាង ៨០ នាក់ នៅក្នុងនោះមាននិស្សិត និងសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យជាតិឡាវ និងបុគ្គលិកលេខាធិការដ្ឋាន MRC ផងដែរ។

ពេលផ្តល់រង្វាន់ដល់ជ័យលាភីក្នុងពិធីនេះ នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC លោក ផាំ ទាន់ ផាន (Pham Tuan Phan) បានមានប្រសាសន៍ថា លោកសូមវាយតម្លៃខ្ពស់ចំពោះគុណតម្លៃដែលបេក្ខជនចូលរួមក្នុងការប្រកួតប្រជែងនេះ ផ្តល់ដល់ទន្លេ និងទំនាក់ទំនងដ៏ជិតស្និទ្ធដែលពួកគេមានជាមួយនឹងទន្លេនេះ។

លោក ផាំ បានមានប្រាសាសន៍ថា "តាមរយៈរឿងរ៉ាវរាប់រយនេះ ខ្ញុំបានឃើញពីសារៈសំខាន់នៃទន្លេមេគង្គ និងទំនាក់ទំនងដ៏ជិតស្និទ្ធ ដែលប្រជាជនទូទៅមានជាមួយទន្លេនេះ។ ប្រការនេះ ជំរុញលើកទឹកចិត្តដល់យើងទាំងអស់គ្នា និងប្រាប់យើងទាំងអស់គ្នាពីមូលហេតុដែលកិច្ចសហប្រតិបត្តិការរបស់យើងមានសារៈសំខាន់ ក្នុងការការពារ និងអភិវឌ្ឍន៍ទន្លេនេះ ប្រកបដោយការទទួលខុសត្រូវ និងសំខាន់ជាងគេនោះ គឺមូលហេតុដែល MRC គឺជាស្ថាប័នដ៏សំខាន់"។

ដៃគូអភិវឌ្ឍន៍របស់ MRC ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នេះផងដែរ បានចូលរួមជាមួយនឹងការវាយតម្លៃរបស់លោកនាយកប្រតិបត្តិ។ លោក អ៊ុនហឿន សៃយ៉ាសិទ្ធ (Ounheuan Saiyasith) មកពីស្ថានទូតអូស្ត្រាលី ប្រចាំទីក្រុងវៀងចន្ទ បានមានប្រសាសន៍ថា លោកមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលបានស្តាប់ឮពីការផ្តល់សារៈសំខាន់ដល់ទន្លេនេះ ពីសំណាក់ជ័យលាភី និងអ្នកចូលរួមប្រកួតប្រជែងដ៏ច្រើននាក់បែបនេះ។

"សំណេររឿងដែលជ័យលាភីលើកឡើងទាំងនេះ ផ្តល់នូវភាពកក់ក្តៅ និងធ្វើឱ្យការងាររួមរបស់យើងកាន់តែមានភាពរស់រវើក។ ដើម្បីការពារគុណតម្លៃនេះ និងដើម្បីខិតខំធ្វើឱ្យមានតុល្យភាពរវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន មិនមែនជាការងារងាយស្រួលនោះឡើយ។ MRC សមនឹងទទួលបានការគាំទ្រឱ្យបានច្រើន តាមដែលអាចធ្វើបាន។"

ការប្រកួតនិពន្ធរឿងខ្លី ដែលដំណើរការកាលពីដើមឆ្នាំនេះ បើកចំហចំពោះប្រជាពលរដ្ឋ និងអ្នកដែលរស់នៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម គ្រប់វ័យទាំងអស់។ ការប្រកួតប្រជែងនេះមានគោលបំណងអបអរសាទរទិវាមេគង្គ ជាថ្ងៃដែលកិច្ចព្រមព្រៀងមេគង្គ ត្រូវបានចុះហត្ថលេខា កាលពីឆ្នាំ ១៩៩៥ និងដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការសម្របសម្រួលរៀបចំផែនការ និងគ្រប់គ្រងតំបន់អាងទន្លេមេគង្គ។ អ្នកចូលរួមក្នុងការប្រកួតប្រជែង ត្រូវបានស្នើឱ្យសរសេរជាសំណេរជាភាសាអង់គ្លេស ឬភាសាជាតិរបស់ពួកគេ មិនឱ្យលើសពី ៦០ ពាក្យ។

សំណេរដែលទទួលបានជ័យលាភីទាំង ១២ ត្រូវបានដាក់តាំងបង្ហាញក្នុងសន្និសីទអន្តរជាតិរបស់ MRC ដែលរៀបចំឡើងកាលពីពេលថ្មីៗនេះ និងក្នុងអំឡុងទិវាមេគង្គ និងបានបង្ហាញជូនថ្នាក់ដឹកនាំមកពីប្រទេសជាប់ទន្លេមេគង្គ ក្នុងកិច្ចប្រជុំកំពូលលើកទី ៣ របស់ MRC។ អត្ថបទទាំងនេះ ក៏នឹងបង្ហាញក្នុងផលិតផលផ្សេងទៀតរបស់ MRC ផងដែរ។

នេះគឺជាការប្រកួតប្រជែងសំណេរថ្នាក់តំបន់លើកទី ១ ដែលរៀបចំដោយ MRC បន្ទាប់ពីការរៀបចំពិពណ៌រូបថតលើកទី ១ របស់គណៈកម្មការនេះ កាលពីចុងឆ្នាំមុន និងមានរូបថតចូលរួមចំនួន ១៦៥ សន្លឹក ដោយអ្នកថតរូបមិនមែនអាជីពចំនួន ៤២ នាក់។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

-**ចប់**-

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុភក្រ្ត
មន្ត្រីទំនាក់ទំនងស្តីទីជាមួយអ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263, ភ្ជាប់បន្ត 4070
ទូរសព្ទដៃ៖ +856-20-77779168

###